ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០២-២០៦ ប្រ.ក.

# ប្រកាស

## ស្តីពី

## និតិវិធីជាបទដ្ឋានសំរាប់ការកំណត់អត្តសញ្ញាណនៃការសំអាតប្រាក់ នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី ១៨ ខែវិច្ឆកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០២០២/០៣៩ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០២ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាថ្មីម្តងទៀត
- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

## សំរេច

**ប្រការ ១.-**

កំណត់នីតិវិធីជាបទដ្ឋានសំរាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា តទៅនេះហៅថាគ្រឹះស្ថានហិរញ្ញវត្ថុក្នុងការធ្វើស្វ័យត្រួតពិនិត្យរបស់អតិថិជន និងសំរាប់កំណត់អត្តសញ្ញាណនៃការសំអាតប្រាក់ ។

**ប្រការ ២.-**

គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវបង្កើត គ្រប់គ្រងនិងរក្សាទុកកម្មវិធីមួយដែលធានានិងតាមដានអោយ

មានប្រសិទ្ធភាពទូវសកម្មភាពប្រឆាំងការសំអាតប្រាក់ដែលត្រូវអនុវត្តតាមប្រកាសនេះ ។ កម្មវិធីអនុវត្តផ្ទៃក្នុងរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវសរសេរជាលាយលក្ខណ៍អក្សរបានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាលដោយមានកំណត់ហេតុប្រជុំ ។ គោលនយោបាយនេះត្រូវរួមមាន ៖

- ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដើម្បីធានាការអនុវត្តន៍ជាប្រចាំ
- ការសាកល្បងដោយឯករាជ្យបញ្ជាក់ពីការអនុវត្តន៍
- ការសម្របសម្រួលនិងការតាមដានពិនិត្យប្រចាំថ្ងៃ ដោយបុគ្គលិក១រូបដែលបានតែងតាំង
- ការបណ្តុះបណ្តាលបុគ្គលិក ។

**ប្រការ ៣.-**

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវយកចិត្តទុកដាក់ចំពោះអត្តសញ្ញាណរបស់អតិថិជន ។ ការបើកគណនីអនាមិកត្រូវបានហាមឃាត់ជាដាច់ខាត ។ ត្រូវរិតត្បិតចំពោះក្រុមហ៊ុនដែលបានបើកគណនីហើយពុំមានសកម្មភាព ។ ចំពោះអតិថិជនជាក្រុមហ៊ុនត្រូវសំគាល់អត្តសញ្ញាណភាគទុនិកអោយបានច្បាស់លាស់ និងជាអចិន្រ្តៃយ៍ ។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវផ្អែកលើអត្តសញ្ញាណរបស់អតិថិជន ដែលមាននៅលើឯកសារផ្លូវការបើមិនទាន់បានស្គាល់អតិថិជនពីមុនមកទេ ។

**ប្រការ ៤.-**

ដើម្បីធានាអោយប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងមានប្រសិទ្ធភាព គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបង្ហាញនូវការប្តេជ្ញាអនុវត្តដោយបង្កើតគោលនយោបាយត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់មួយរួមមាន : ការបើកគណនី ការតាមដានត្រួតពិនិត្យ និងនីតិវិធីរាយការណ៍អំពីរូបិយវត្ថុដោយផ្ញើជូនទៅអ្នកគ្រប់គ្រងជាន់ខ្ពស់ជាប្រចាំ ។

**ប្រការ ៥.-**

ស្នងការគណនីឯករាជ្យ ឬអ្នកត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានហិរញ្ញវត្ថុត្រូវ ៖

១.បង្ហាញពីភាពសុចរិតនិងប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រង និងការអនុវត្តន៍ប្រកាសនេះ

២.សាកល្បងលើប្រតិបត្តិការគ្រប់ផ្នែកប្រតិបត្តិការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ពិសេសផ្នែកដែលមានហានិភ័យខ្ពស់ ផលិតផល និងសេវាកម្ម

៣.វាយតម្លៃលើភាពគ្រប់គ្រាន់នៃវិធីសាស្ត្ររបស់គ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីរកអោយឃើញសកម្មភាពសង្ស័យ ។

**ប្រការ ៦.-**

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវកត់ត្រា និងរក្សាទុកឯកសារសំរាប់រយៈពេល១០ឆ្នាំ នូវរាល់ប្រតិបត្តិការណាដែលស្មើឬលើសពី៤០លានរៀល ឬជារូបិយប័ណ្ណផ្សេងទៀតដែលមានតំលៃស្មើ ។ ប្រតិបត្តិការច្រើនលើកត្រូវបានចាត់ថាជាប្រតិបត្តិការតែមួយ ប្រសិនបើប្រតិបត្តិការទាំងនេះត្រូវបានធ្វើជាផលប្រយោជន៍ចំពោះបុគ្គលតែមួយ ។

**ប្រការ ៧.-**

គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវរាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជា ចំពោះប្រតិបត្តិការសង្ស័យណាដែលពាក់ព័ន្ធនឹងការរំលោភច្បាប់ ឬបទបញ្ញត្តិ ។ ការផ្តល់ពត៌មានពីរបាយការណ៍សកម្មភាពសង្ស័យទៅអោយអតិថិជនត្រូវបានហាមឃាត់ដាច់ខាត ។

**ប្រការ ៨.-**

គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធានាបណ្តុះបណ្តាលជាប្រចាំនូវបុគ្គលិកទាំងអស់ រួមទាំងអ្នកគ្រប់គ្រងជាន់ខ្ពស់អំពីបញ្ញត្តិរបស់ប្រកាសនេះ ព្រមទាំងគោលនយោបាយនិងនីតិវិធីផ្ទៃក្នុងដើម្បីប្រឆាំងការសំអាតប្រាក់។ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវធ្វើវិសោធនកម្មលើកិច្ចសន្យាការងារឯកត្តជននិងបទបញ្ជាផ្ទៃក្នុងដើម្បីធានាការពារ ជាពិសេសចំពោះនិយោជិកដែលត្រូវធ្វើរបាយការណ៍មកធនាគារជាតិនៃកម្ពុជាតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ ៩.-**

ការខកខានមិនអនុវត្តបានត្រឹមត្រូវតាមបញ្ញត្តិណាមួយនៃប្រកាសនេះ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវទទួលរងនូវទណ្ឌកម្មដូចមានចែងនៅមាត្រា៥២ និង៥៥ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ១០.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្ត ម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ១១.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០២

**ទេសាភិបាល**

ជា ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"